EVERETT PUBLIC SCHOOLS

P3 Cross District Coalition

# គោលការណ៍ណែនាំក្នុងការត្រៀមខ្លួនសំរាប់ចូលថ្នាក់សាលាមត្តេយ្យឆ្នាំ 2014

ឪពុកម្តាយនិងគ្រួសារមានតួនាទីសំខាន់ណាស់ធ្វើជាគ្រូទីមួយសំរាប់កូនរបស់ពួកគេ។ ក្មេងរៀនទៅតាមរបៀបផ្សេងៗពីគ្នានិងទៅតាមកំរិតផ្សេងៗពីគ្នា ផងដែរ។ ពួកគេចូលរៀននៅសាលាមានជំនាញការខុសៗគ្នា។ គោលការណ៍ណែនាំនេះលើកបង្ហាញនូវជំនាញការខ្លះៗដែលក្មេងត្រូវការដើម្បីត្រៀមខ្លួន ចូលរៀនក្នុងថ្នាក់សាលាមត្តេយ្យ។ បញ្ជីរនៅខាងក្រោមនេះផ្តល់ជាយោបល់នូវរបៀបផ្សេងៗក្នុងការធ្វើកិច្ចការជាមួយកូនរបស់លោកអ្នកដើម្បីជួយដល់ ពួកគេអោយត្រៀមខ្លួនរួចជាស្រេចសំរាប់ចូលរៀន។

| | ផ្នែកសង្គម/ផ្នែកអារម្មណ៍ | យើងកំពុងតែធ្វើ | កូនរបស់ខ្ញុំអាចធ្វើបាន |
|---|---|---|---|
| 1 | កូនរបស់ខ្ញុំអាចធ្វើតាមការណែនាំ 2 ដំណាក់ការណ៍ជាប់ៗគ្នា ហើយនឹងចាប់ផ្តើមធ្វើតាមការណែនាំ 3 ដំណាក់ការណ៍។ | | |
| 2 | កូនរបស់ខ្ញុំអាចចងចាំនិងធ្វើតាមទម្លាប់ដដែលៗ (ឧទាហរណ៍: ញ៉ាំបាយល្ងាច ងូតទឹក ដុះធ្មេញ អានសៀវភៅរឿងមុនពេលដេក ចូលទៅដេក)។ | | |
| 3 | កូនរបស់ខ្ញុំអាចនិយាយប្រាប់អំពីអារម្មណ៍ផ្ទាល់ខ្លួនរបស់គេ (ឧទាហរណ៍: ខ្ញុំសប្បាយចិត្ត ខ្ញុំកើតទុក ខ្ញុំរំភើប)។   | | |
| 4 | កូនរបស់ខ្ញុំអាចរម្ងាប់ចិត្តដោយខ្លួនឯងបាន នៅពេលណាមួរម៉ៅ ឬខឹងតូចចិត្ត។ | | |
| 5 | កូនរបស់ខ្ញុំអាចពាក់អាវធំដោយខ្លួនឯងបាន។  | | |
| 6 | កូនរបស់ខ្ញុំអាចប្រើបន្ទប់ទឹកដោយខ្លួនឯង។  | | |
| 7 | កូនរបស់ខ្ញុំអាចលាងដៃរបស់គេ។ | | |
| 8 | កូនរបស់ខ្ញុំអាចដាក់ប្រដាប់ប្រដាលេងនៅកន្លែងដើមវិញ ជូតសំអាតការក្រពប់ និងសំអាតខ្លួនឯង។  | | |
| 9 | កូនរបស់ខ្ញុំចេះចែករំលែក ចាំវេនខ្លួនឯង និងចេះជួយអ្នកដទៃ។ | | |
| 10 | កូនរបស់ខ្ញុំចេះសម្របខ្លួនទៅតាមស្ថានការណ៍ថ្មីឬមនុស្សមិនដែលស្គាល់។  | | |
| 11 | កូនរបស់ខ្ញុំអាចលេងត្រូវគ្នាជាមួយក្មេងដទៃ។ | | |
| 12 | កូនរបស់ខ្ញុំចេះលួងលោមក្មេងដទៃ។ | | |
| 13 | កូនរបស់ខ្ញុំមានឱកាសលេងជាញឹកញាប់ជាមួយមិត្តភ្កិដដែលដែលមានអាយុស្មើគ្នា។ | | |

| | ផ្នែករាងកាយ | យើងកំពុងតែធ្វើ | កូនរបស់ខ្ញុំអាចធ្វើបាន |
|---|---|---|---|
| 1 | កូនរបស់ខ្ញុំអាចរត់ លោត និងអាចរត់លឿន។ | | |
| 2 | កូនរបស់ខ្ញុំអាចឈរជើងមួយ។ | | |
| 3 | កូនរបស់ខ្ញុំអាចគ្រវែងនិងចាប់បាល់ធំ។  | | |
| 4 | កូនរបស់ខ្ញុំអាចទាត់បាល់។ | | |
| 5 | កូនរបស់ខ្ញុំអាចកាត់ដោយប្រើកន្ត្រៃ។  | | |
| 6 | កូនរបស់ខ្ញុំអាចកាន់និងប្រើដៃខ្មៅ។ | | |
| 7 | កូនរបស់ខ្ញុំអាចដាក់ខ្សែក្រវ៉ាត់ រូតអាវ ទាញកន្ត្រាក់ និងបិទឡេវអាវ។    | | |

| | ភាសា | យើងកំពុងតែធ្វើ | កូនរបស់ខ្ញុំអាចធ្វើបាន |
|---|---|---|---|
| 1 | កូនរបស់ខ្ញុំអាចប្រើពាក្យដើម្បីនិយាយចេញនូវគំនិតនិងអ្វីដែលគេត្រូវការ។ | | |
| 2 | កូនរបស់ខ្ញុំអាចដាក់ឈ្មោះនិងពិព័ណនាវត្ថុដែលធ្លាប់ស្គាល់នៅក្នុងពិភពរបស់គេ។ | | |
| 3 | កូនរបស់ខ្ញុំប្រើពាក្យថ្មីៗជារៀងរាល់ថ្ងៃ។   | | |
| 4 | កូនរបស់ខ្ញុំនិយាយបានច្បាស់ៗហើយមនុស្សភាគច្រើនអាចយល់បាន។ | | |
| 5 | កូនរបស់ខ្ញុំអាចនិយាយប្រយោគដែលមាន 4-6 ពាក្យ។ | | |
| 6 | កូនរបស់ខ្ញុំអាចនិយាយប្រាប់រឿងដែលកន្លងរួចទៅហើយ ដោយក្បោះក្បាយ។ | | |
| 7 | កូនរបស់ខ្ញុំអាចសន្ទនាលើប្រធានតែមួយជាមួយអ្នកដទៃ ដោយចេះចែកវេនគ្នានិយាយ។ | | |

| | ផ្នែកការយល់ដឹង | យើងកំពុងតែធ្វើ | កូនរបស់ខ្ញុំ អាចធ្វើបាន |
|---|---|---|---|
| 1 | កូនរបស់ខ្ញុំអាចគិតឃើញច្រើនរបៀបក្នុងការដោះស្រាយចំណោទ។ | | |
| 2 | កូនរបស់ខ្ញុំបង្ហាញនូវភាពចង់ដឹងចង់ឮរួចហើយស្វែងរកចម្លើយ។ | | |
| 3 | កូនរបស់ខ្ញុំបង្ហាញនូវភាពរហ័សរហួននិងបញ្ញាវាងវៃក្នុងការលេងនិងដោះស្រាយចំណោទ។ | | |
| 4 | កូនរបស់ខ្ញុំអាចដាក់វត្ថុជាក្រុមទៅតាមព៌ណ ទ្រង់ទ្រាយ និង ទំហំ ជាដើម ។ល។ | | |
| 5 | កូនរបស់ខ្ញុំអាចអង្គុយស្ងៀម ផ្ដោតអារម្មណ៍ និងធ្វើកិច្ចការនៅមួយកន្លែង។ | | |



| | អក្ខរភាព | យើងកំពុងតែធ្វើ | កូនរបស់ខ្ញុំ អាចធ្វើបាន |
|---|---|---|---|
| 1 | កូនរបស់ខ្ញុំចេះពាក្យជួនគ្នា 5-10 ពាក្យ ឬចម្រៀងរបស់កូនក្មេង។ | | |
| 2 | កូនរបស់ខ្ញុំដឹងបើសិនជាពាក្យផ្ដើមឡើងដោយមានសម្លេងដូចគ្នា (ឧទាហរណ៍: big, brown, bear)។ | | |
| 3 | កូនរបស់ខ្ញុំអាចស្ដាប់ដឹងព្យាង្គរបស់ពាក្យ (ឧទាហរណ៍: hap-py មាន 2 ព្យាង្គ)។ | | |
| 4 | កូនរបស់ខ្ញុំស្គាល់និងដាក់ឈ្មោះតួអក្សរតូច និងតួអក្សរធំ 10-20 តួ។ | | |
| 5 | កូនរបស់ខ្ញុំបញ្ចេញសម្លេងត្រូវសម្រាប់អក្សរ 10-20 អក្សរ។ | | |
| 6 | កូនរបស់ខ្ញុំស្គាល់ផ្នែកទាំងអស់នៃសៀវភៅ: គម្រប ចំណងជើង ទំព័រ និង ពាក្យ ជាដើម ។ល។ | | |
| 7 | កូនរបស់ខ្ញុំអានសៀវភៅជាមួយមនុស្សធំ ឬស្ដាប់រឿងជារៀងរាល់ថ្ងៃ គេអាចនិយាយប្រាប់សាច់រឿងសារឡើងវិញ។ | | |
| 8 | កូនរបស់ខ្ញុំ "សរសេរ" រឿងដោយមានគូររូបនិងប្រើតួអក្សរ។ | | |
| 9 | កូនរបស់ខ្ញុំអាចសរសេរឈ្មោះរបស់គេហើយស្គាល់តួអក្សរ។ | | |
| 10 | កូនរបស់ខ្ញុំអាចនិយាយតួអក្សរនិមួយៗ។ | | |









| | គណិតសាស្ត្រ | យើងកំពុងតែធ្វើ | កូនរបស់ខ្ញុំ អាចធ្វើបាន |
|---|---|---|---|
| 1 | កូនរបស់ខ្ញុំអាចរាប់វត្ថុ 10-20 វត្ថុ ដោយចង្អុលវត្ថុនិមួយៗ។ | | |
| 2 | កូនរបស់ខ្ញុំអាចរាប់ឮៗ តាមលំដាប់ រហូតដល់លេខ 20។ | | |
| 3 | កូនរបស់ខ្ញុំចាប់ផ្ដើមយល់និងប្រើពាក្យច្រើន តិច ហើយនិងនៅដដែល។ | | |
| 4 | កូនរបស់ខ្ញុំអាចស្គាល់លេខពី 1-10។ | | |
| 5 | កូនរបស់ខ្ញុំភ្ជាប់លេខពី 1-10 ជាមួយនឹងវត្ថុដែលត្រូវគ្នា។ | | |
| 6 | កូនរបស់ខ្ញុំស្គាល់ទ្រង់ទ្រាយសាមញ្ញ (ឧទាហរណ៍: រង្វង់មូល ការេបួនជ្រុង ត្រីកោណ ចតុកោណ)។ | | |
| 7 | កូនរបស់ខ្ញុំដាក់តម្រូវគ្នានិងដាក់ដោយឡែកពីគ្នានូវទ្រង់ទ្រាយសាមញ្ញ។ | | |
| 8 | កូនរបស់ខ្ញុំប្រើប្រដាប់ជ្រាវស់វែងពេលលេង (ឧទាហរណ៍: ពែង ស្លាបព្រា បន្ទាត់ ជញ្ជីង)។ | | |
| 9 | កូនរបស់ខ្ញុំប្រើពាក្យដើម្បីពិព៌ណនាវត្ថុទៅតាមទំហំ ទ្រង់ទ្រាយ និងទម្ងន់ (ឧទាហរណ៍: ធំ មូល ធ្ងន់)។ | | |
| 10 | កូនរបស់ខ្ញុំអាចដាក់វត្ថុទៅតាមលំដាប់ថ្នាក់ (ឧទាហរណ៍: ទីមួយ ទីពីរ ទីបី)។ | | |





| | ដណឹងផ្ទាល់ខ្លួន | យើងកំពុងតែធ្វើ | កូនរបស់ខ្ញុំ អាចធ្វើបាន |
|---|---|---|---|
| 1 | កូនរបស់ខ្ញុំស្គាល់ឈ្មោះខ្លួន ឈ្មោះត្រកូល និង ឈ្មោះឪពុកម្ដាយ។ | | |
| 2 | កូនរបស់ខ្ញុំស្គាល់អាស័យដ្ឋានផ្ទះនិងលេខទូរស័ព្ទ។ | | |
| 3 | កូនរបស់ខ្ញុំអាចស្គាល់ 10 ឈ្មោះនៅលើខ្លួនប្រាណ (ក្បាល ស្មា ជង្គង់ ម្រាមដៃ ជាដើម ។ល។ | | |
| 4 | កូនរបស់ខ្ញុំស្គាល់អាយុនិងថ្ងៃ-ខែ-ឆ្នាំកំណើតរបស់ខ្លួនឯង។ | | |






Developed by the PreK-3 Cross District Coalition of Edmonds, Everett, Federal Way, Highline and Seattle Public Schools. Aligned with Teaching Strategies GOLD, WaKIDS (Washington Kindergarten Inventory of Developing Skills) Progressions of Development & Learning and adapted from Characteristics of Children Entering Kindergarten. Changes will not be made to this document without the written consent of the PreK-3 Cross District Coalition. Funded by the Bill & Melinda Gates Foundation. January 2014.

Cambodian